**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

៚✻៛

ក្រសួងសុខាភិបាល

លេខ ១៤៤ ស.ស.

ថ្ងៃអង្គារ ៦រោច ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ,ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៩

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

**សូមជម្រាបជូន**

**ឯកឧត្តមប្រធានលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិ**

**សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ**

**កម្មវត្ថុ:** ការផ្ទេរមុខងារវិស័យសុខាភិបាល ប្រគល់ឱ្យទៅរដ្ឋបាលក្រុង ស្រុក ។

**យោង:**
- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។
- អនុក្រឹត្យលេខ ៦៨ អនក្រ.បក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១២ ស្តីពីដំណើរការទូទៅនៃការផ្ទេរមុខងារនិងធនធានឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ។
- លិខិតលេខ ១៣០ សជណ.មយ ចុះថ្ងៃទី ២៩ ខែមករា ឆ្នាំ២០១៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីការលើសំណើគោលការណ៍ដឹកនាំលើចំណុចសំខាន់ៗនៃការកែសម្រួលរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងនៅថ្នាក់ក្រុង ស្រុក ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមប្រធានលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(គ.ជ.អ.ប) មេត្តាជ្រាបថា ក្រសួងសុខាភិបាលសូមគាំទ្រចំពោះគោលការណ៍កែសម្រួលរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងនៅថ្នាក់ក្រុង ស្រុក ដើម្បីធានាដល់ការកាត់បន្ថយបន្ទុកចំណាយនិងពង្រឹងរចនាសម្ព័ន្ធស្ថាប័ន ដោយការធ្វើសមាហរណកម្មការិយាល័យជំនាញរបស់ក្រសួង ស្ថាប័ន ទៅក្នុងរចនាសម្ព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលក្រុង ស្រុក លើកលែងតែវិស័យជាអាទិភាពសំខាន់ៗមួយចំនួន ដូចជា អប់រំ សុខាភិបាល និងនគរូបនីយកម្ម ដែលចាំបាច់ត្រូវបង្កើតជាអង្គភាពដាច់ដោយឡែកៗពីគ្នា(គោលការណ៍ទី២នៃលិខិតលេខ១៣០ សជណ.មយ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៩) របស់ទីស្តីការគណៈរដ្ឋមន្ត្រី។ បន្ទាប់ពីការប្រជុំកាលពីថ្ងៃទី១៤ខែមីនា ឆ្នាំ២០១៩ នៅលេខាធិការដ្ឋាននៃ គ.ជ.អ.ប ស្តីពីការកំណត់មុខងារជាក់លាក់សម្រាប់ផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ក្រសួងសុខាភិបាលបានធ្វើការប្រជុំផ្ទៃក្នុងមួយ ដើម្បីពិភាក្សាក្នុងការកំណត់មុខងារជាក់លាក់សម្រាប់ផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ដោយគិតពិចារណាចំពោះមុខងារណាមានការខានជាអប្បបរមា ទៅលើប្រតិបត្តិការដែលកំពុងដំណើរការរបស់រាជរដ្ឋាភិបាល និងការគាំទ្រពីអ្នកពាក់ព័ន្ធនានា ផ្អែកលើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នៅជំពូកទី៥ផ្នែកទី២ ស្តីពីមុខងារត្រង់មាត្រា២១៥,២១៦,២១៧និង២១៨ និងអនុក្រឹត្យលេខ ៦៨ អនក្រ.បក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១២ នៅជំពូកទី៣ អន្តរប្បញ្ញត្តិផ្នែកទី១ ស្តីពីដំណើរ

ʔ

ការផ្ទេរមុខងារ និងធនធានសម្រាប់វិស័យឬកិច្ចអាទិភាព ដែលបានបញ្ជាក់ពីការផ្ដល់អាទិភាពដល់បញ្ហាទាក់ទងនឹងសុខាភិបាល អាហារូបត្ថម្ភ និងសេវាប្រជាជន រួមទាំងតម្រូវការផ្សេងៗរបស់ស្ត្រី បុរស យុវវ័យ កុមារ ជនរងគ្រោះ និងជនជាតិដើមភាគតិច។ តាមរយៈការប្រជុំនេះ ក្រសួងសុខាភិបាលស្នើផ្ទេរមុខងារវិស័យសុខាភិបាលមួយចំនួន ប្រគល់ឱ្យទៅរដ្ឋបាលក្រុង ស្រុក ដូចខាងក្រោម៖

- គ្រប់គ្រងនិងផ្ដល់លិខិតអនុញ្ញាត៖
    - លិខិតអនុញ្ញាតស្នើសុំបើកថ្មី បន្តសុពលភាពនិងប្តូរទីតាំងបន្ទប់ពិនិត្យស្ត្រីមានផ្ទៃពោះមុននិងក្រោយសម្រាល
    - លិខិតអនុញ្ញាតស្នើសុំបើកថ្មី បន្តសុពលភាពនិងប្តូរទីតាំងបន្ទប់ថែទាំជំងឺ
    - លិខិតអនុញ្ញាតស្នើសុំបើកថ្មី បន្តសុពលភាពនិងប្តូរទីតាំងបន្ទប់ព្យាបាលដោយចលនា
    - លិខិតអនុញ្ញាតស្នើសុំបើកថ្មី បន្តសុពលភាពនិងប្តូរឈ្មោះឱសថការីនៃឱសថស្ថានរង ក
    - លិខិតអនុញ្ញាតបន្តសុពលភាពឱសថស្ថានរង ខ
    - លិខិតអនុញ្ញាតស្នើសុំបើកថ្មី បន្តសុពលភាពនិងប្តូរទីតាំងបន្ទប់ពិគ្រោះព្យាបាលជំងឺទូទៅ
    - លិខិតអនុញ្ញាតស្នើសុំបើកថ្មី បន្តសុពលភាពនិងប្តូរទីតាំងបន្ទប់ពិគ្រោះព្យាបាលជំងឺមាត់ធ្មេញ
    - ការផ្តល់វិញ្ញាបនប័ត្របញ្ជាក់អនាម័យចំណីអាហារតាមភោជនីយដ្ឋាននិងអាហារដ្ឋានដែលមានចំណុះចាប់ពី៥០កៅអីចុះក្រោម។
- ចូលរួមអប់រំផ្សព្វផ្សាយអាហារូបត្ថម្ភ អនាម័យចំណីអាហារ សុខភាពមាតា យុវវ័យ និងកុមារ។
- ចូលរួមអប់រំបង្ការជំងឺឆ្លងមានជាអាទិ៍ ជំងឺអេដស៍ របេង គ្រុនចាញ់ គ្រុនឈាម និងជំងឺមិនឆ្លងសំខាន់ៗដល់សហគមន៍ រួមទាំងគ្រោះថ្នាក់បង្កដោយថ្នាំជក់ គ្រឿងស្រវឹង។
- ជួយចាត់ចែងបញ្ជូនអ្នកជំងឺនិងស្ត្រីមានផ្ទៃពោះប្រឈមនឹងហានិភ័យ ពិសេសប្រជាពលរដ្ឋក្រីក្រ ងាយរងគ្រោះ ពីភូមិមកមណ្ឌលសុខភាពឬមន្ទីរពេទ្យបង្អែក។
- ជួយអប់រំយុវជនញៀនថ្នាំនិងបញ្ជូនអ្នកញៀនថ្នាំមកព្យាបាល។
- ផ្ដល់ព័ត៌មានដល់សហគមន៍អំពីសេវាដែលមាននៅមណ្ឌលសុខភាពនិងមន្ទីរពេទ្យបង្អែក។
- ផ្ដល់ព័ត៌មានដល់មូលដ្ឋានសុខាភិបាលអំពីបញ្ហាសុខភាពនៅសហគមន៍។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមប្រធានលេខាធិការដ្ឋានគ.ជ.អ.ប មេត្តាពិនិត្យ និងសម្រេច តាមការគួរ ។

សូមឯកឧត្តម មេត្តាទទួលនូវការគោរពរាប់អានពីខ្ញុំ។ 1/2/14

ម៉ម_ប៊ុនហេង